**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
~~~***~~~

សាលាដំបូងខេត្តកណ្ដាល
លេខក្រមព្រហ្មទណ្ឌលេខ: ០២២(ឍ)
ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
កណ្ដាល, ថ្ងៃទី 21 ខែ 02 ឆ្នាំ 2023
ក្រឡាបញ្ជី
[redacted]

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល នាថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងខេត្តកណ្ដាល
លោក ចៅក្រមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងខេត្តកណ្ដាល
លោក ចៅក្រមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**មេធាវី**

លោក [redacted] មេធាវីការពារក្ដីឲ្យជនជាប់ចោទឈ្មោះ [redacted] សាវ៉ាន់ និង ឈ្មោះ [redacted] យុទ្ធរ៉ា
លោក [redacted] មេធាវីការពារក្ដីឲ្យជនជាប់ចោទឈ្មោះ [redacted] មាន
លោក មេធាវីការពារក្ដីឲ្យជនជាប់ចោទឈ្មោះ [redacted] សុចាន់ ហៅ តន
លោក មេធាវីការពារក្ដីឲ្យជនជាប់ចោទឈ្មោះ [redacted] ហុងម៉េង,ឈ្មោះ [redacted] វឌ្ឍនា ,ឈ្មោះ [redacted] វិសាល ,ឈ្មោះ [redacted] មាស និងឈ្មោះ [redacted] វណ្ណៈ ,ឈ្មោះ [redacted] ណោត ,ឈ្មោះ [redacted] ចិន និងឈ្មោះ [redacted] ទ្រី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: ៣៧៨អក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] ណោត ហៅ ឆែប ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] វ៉ាន់ (រស់) ម្ដាយ ឈ្មោះ [redacted] លាងហ៊ី (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ឃុំខ្លួន១៧.០៣.២២)

២.ឈ្មោះ [redacted] សុចាន់ ហៅ តន ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និង ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ឡាត់ (រស់) ម្ដាយឈ្មោះ [redacted] និន (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។ (ឃុំខ្លួន១៧.០៣.២២)
~~~

៣.ឈ្មោះ [redacted] មាស ហៅ វេហា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ជី (រស់) ម្ដាយឈ្មោះ [redacted] កា (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន ។ (ឃុំខ្លួន ១៩.១២.២០២២)

៤. ឈ្មោះ [redacted] ហុងម៉េង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើតភូមិ [redacted] ឃុ [redacted] ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ស្រ៊ូ (រស់) ម្ដាយឈ្មោះ [redacted] ម៉ុន (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

៥.ឈ្មោះ [redacted] យុទ្ធា ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ជិនដឿង (រស់) ម្ដាយឈ្មោះ [redacted] ចិន្ដា (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

៦.ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ស្រ៊ូ (រស់) ម្ដាយឈ្មោះ [redacted] ថន (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

៧.ឈ្មោះ [redacted] សារ៉ាន់ ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ស (រស់) ម្ដាយឈ្មោះ [redacted] ធា (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

៨.ឈ្មោះ [redacted] មាន ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតភូមិចុង [redacted] ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ម៉េង (រស់) ម្ដាយឈ្មោះ [redacted] ហៀក (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

៩.ឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ជាអនីតិជន ទោសពីមុនគ្មាន ។ (គេចខ្លួន)

១០.ឈ្មោះ [redacted] វត្ត ហៅ [redacted] វឌ្ឍនា ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] (រស់) ម្ដាយ ឈ្មោះ [redacted] ស្រាម (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (គេចខ្លួន)

១១.ឈ្មោះ [redacted] ទ្រី ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈឈ្មោះ [redacted] ពី (រស់) ម្ដាយឈ្មោះ [redacted] គាន (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (គេចខ្លួន)

១២.ឈ្មោះ [redacted] ចិន ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈឈ្មោះ [redacted] ប៊ិន (រស់) ម្ដាយឈ្មោះ [redacted] ថេម (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (គេចខ្លួន)

ពីបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រ៊ង ភេទប្រុស អាយុ៤០ឆ្នាំ មុខរបរ កម្មករសំណង់ ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្ដាល។(ត្រូវជាឪពុករបស់ជនរងគ្រោះ)។



Scanned with CamScanner

## ដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង១៤ និង៣០នាទី មានជនរងគ្រោះឈ្មោះ [redacted] ម៉េងហុង បានជិះម៉ូតូមួយគ្រឿង និងឈ្មោះ [redacted] ណាក់ បានជិះម៉ូតូមួយគ្រឿងទៀតឌុបឈ្មោះ [redacted] សុខុម ទៅលេងផ្ទះគូដណ្តឹងរបស់ឈ្មោះ [redacted] ណាក់ ស្ថិតនៅភូមិព្រែកឫស្សី ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ។ នៅពេលត្រឡប់មកវិញដល់ចំណុចវត្តជ្រោយតាកែវស្ថិតនៅភូមិព្រែកកំពង់ជរ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល ស្រាប់តែមានក្រុមរបស់ជនត្រូវចោទ មានឈ្មោះ [redacted] ណេត ហៅឆែប , ឈ្មោះ [redacted] សុចាន់ ហៅ តន , ឈ្មោះ [redacted] ហុងម៉េង , ឈ្មោះ [redacted] យុទ្ធា , ឈ្មោះ [redacted] ចិន , ឈ្មោះ [redacted] វត្ត ហៅ [redacted] វឌ្ឍនា, ឈ្មោះ [redacted] វិសាល , ឈ្មោះ [redacted] ទ្រី , ឈ្មោះ [redacted] សារ៉ាន់ , ឈ្មោះ [redacted] មាស ហៅ វេហា , ឈ្មោះ [redacted] មាន , ឈ្មោះ [redacted] វណ្ណៈ បានស្រែកហៅឲ្យក្រុមជនរងគ្រោះឈប់ម៉ូតូ ប៉ុន្តែក្រុមជនរងគ្រោះមិនបានឈប់នោះទេ ភ្លាមនោះក្រុមជនត្រូវចោទបាននាំគ្នាជិះម៉ូតូដេញតាមដោយក្នុងដៃមានកាន់ខ្សែក្រវ៉ាត់តាមវាយពីក្រោយ តែមិនត្រូវរហូតមកដល់ក្រោយវត្តដើមពោធិ៍ នៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល បានយកដុំថ្មគប់ទៅលើជនរងគ្រោះឈ្មោះ [redacted] ម៉េងហុង បណ្តាលឲ្យដួលម៉ូតូរួចនាំគ្នាវាយបន្ថែមទៀតបណ្តាលឲ្យឈ្មោះ [redacted] ម៉េងហុង ដួលសន្លប់តែម្តង ឃើញបែបនេះក្រុមជនរងគ្រោះមានឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] សុខុម បានត្រឡប់មកមើលវិញ ចំណែកបក្សពួករបស់ជនត្រូវចោទបាននាំគ្នារត់គេចខ្លួនបាត់អស់ ។ ដោយឃើញសភាពជនរងគ្រោះឈ្មោះ [redacted] ម៉េងហុង មានឈាមចេញតាមមាត់ និងត្រចៀក ទើបឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សំណាង បាននាំជនរងគ្រោះទៅឲ្យគ្រួសារយកទៅមន្ទីរពេទ្យ ខណៈនោះជនរងគ្រោះបានស្លាប់នៅមន្ទីរពេទ្យតែម្តង។ លុះនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ ទើបគ្រួសារជនរងគ្រោះបានមកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍រដ្ឋបាលនគរបាលជ្រោយតាកែវឲ្យជួយអន្តរាគមន៍ ដោយចាប់ឃាត់ខ្លួនបានជនត្រូវចោទឈ្មោះ [redacted] ណេត និងឈ្មោះ [redacted] សុចាន់ ចំណែកជនត្រូវចោទចំនួន១០នាក់ទៀតបានរត់គេចខ្លួនបាត់ទៅ ។

## បានឃើញ

-ដីកាសន្និដ្ឋានស្ថាពរលេខៈ ៩៨៥ ដកសព/២២ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-ដីកាដំណោះស្រាយលេខៈ ១០០០ ដកជស/២២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ។

-ដីកាចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះលេខៈ ១០៨១ ដកចត/២២ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

## នាពេលសវនាការ

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ណេត បានឆ្លើយថាៈ ខ្លួនសូមបដិសេធថាមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយនៅថ្ងៃកើតហេតុខ្លួនមិនបានដឹងរឿងអ្វីនោះទេ ហើយក៏មិនបានចូលរួមធ្វើសកម្មភាពវាយគេដែរ គឺខ្លួននៅវត្តរងចាំឌុបលោកទៅរៀនភាសាអង់គ្លេស ។ ពេលនគរបាលចាប់ខ្លួន គឺខ្លួនកំពុងនៅវត្តកោះ ខ្លួនមិនដឹងថាហេតុអ្វីបានជាគរបាលចាប់រូបខ្លួនទេ ។ ចម្លើយដែលខ្លួនបានឆ្លើយនៅជំណាក់កាលនគរបាលគឺខ្លួមិនទទួលស្គាល់ទេ ព្រោះថាបើមិនឆ្លើយគឺនគរបាលវាយខ្លួន ។ កន្លងមកខ្លួនស្គាល់ឈ្មោះ [redacted] សារ៉ាន់

ជាអ្នករៀនជាមួយគ្នា តែមិនស្គាល់ឈ្មោះ [redacted] ចិន ឈ្មោះ [redacted] វឌ្ឍនា និងឈ្មោះ [redacted] វិសាល ទេ ហើយក៏មិនស្គាល់ក្រុម JTKដែរ ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខចាន់ បានឆ្លើយថា៖ ខ្លួនមិនបានប្រព្រឹត្តដូចជាការចោទប្រកាន់នោះទេ ដោយនៅថ្ងៃកើតហេតុខ្លួនមិនបានវាយគេទេ ខ្លួនគ្រាន់តែអង្គុយនៅលើម៉ូតូ និងនៅបិតស្អុតម៉ូតូឲ្យគេតាំងពីម៉ោង១១ថ្ងៃត្រង់ រហូតដល់ម៉ោង៦ល្ងាច ។ ខ្លួនមិនដែលបានឈ្លោះជាមួយអ្នកណាទេ ហើយក៏មិនស្គាល់ឈ្មោះ [redacted] ម៉េងហុង ដែរ និងមិនដឹងពីរឿងកាប់គ្នានោះដែរ ។ ចម្លើយដែលខ្លួនបានឆ្លើយនៅនគរបាលគឺខ្លួនមិនទទួលស្គាល់ទេ ព្រោះថានគរបាលបានវាយខ្លួនក៏ឆ្លើយថាបានធ្វើទៅ ។ កន្លងមកខ្លួនស្គាល់មិត្តភក្តិឈ្មោះ [redacted] វណ្ណៈ ឈ្មោះ [redacted] មាស ឈ្មោះ [redacted] ទ្រី ឈ្មោះ [redacted] ហុងម៉េង ឈ្មោះ [redacted] ចិន និងឈ្មោះ [redacted] វឌ្ឍនា ដោយសារអ្នករៀនជាមួយគ្នា មិនមែនស្គាល់ទៅវាយគេទេ ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] មាន បានឆ្លើយថា៖ ខ្លួនមិនបានប្រព្រឹត្តដូចជាការចោទប្រកាន់នោះទេ ដោយខ្លួនមិនបានចូលរួមក្នុងការប្រើអំពើហិង្សាទៅលើជនរងគ្រោះនោះទេ ព្រោះថានៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ខ្លួនបានជួយកាប់ជ្រូកថៅកែនៅផ្សារតាខ្មៅ មិនបានស្នាក់នៅភូមិទួលស្វាយជាមួយគ្រួសារនោះទេ ។ ខ្លួនធ្វើជាអ្នកកាប់ជ្រូករយៈពេល០៤ឆ្នាំមកហើយ រាល់ពេល២ ទៅ៣ខែទើបទៅផ្ទះម្តង ។ ថៅកែរបស់ខ្លួនឈ្មោះ [redacted] ផល្លា និងប្រពន្ធឈ្មោះ [redacted] ភ័ស អាចធ្វើជាសាក្សីបាន ហើយខ្លួនក៏មិននៅក្នុងក្រុម JTK ដែរ គ្រាន់តែខ្លួនធ្លាប់បានស្គាល់មនុស្សនៅក្នុងក្រុមនោះខ្លះ ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] មាស បានឆ្លើយថា៖ ខ្លួនសូមបដិសេធនូវការចោទប្រកាន់ ដោយនៅថ្ងៃកើតហេតុ ខ្លួននៅការបងប្អូនស្រីឈ្មោះ ពៅ នៅជិតផ្ទះគ្នាជាមួយខ្លួន ហើយខ្លួនបានចូលរួមការតាំងពីព្រឹកតែអត់មានរូបថតទេ ដោយខ្លួនអត់បានថតរូបជាមួយគេ ។ ខ្លួនពុំមានបងប្អូនឪពុកម្តាយមកធ្វើសាក្សីឲ្យខ្លួនទេពេលនេះ ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វិសាល បានឆ្លើយថា៖ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ ២០២២ ខ្លួនបានទៅដឹកទឹកកកឲ្យគេ ចំណែកពេលរសៀលខ្លួនបានដេកចាំឡានទឹកកកដែលគេយកមកដាក់ពេញមួយថ្ងៃមិនបានទៅណានោះទេ ។ ខ្លួនមិនស្គាល់មនុស្សនៅក្នុងក្រុម JTK មិនស្គាល់ជនរងគ្រោះ និងមិនបានចូលរួមធ្វើសកម្មភាពវាយទៅលើជនរងគ្រោះឡើយ ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សាវ៉ាន់ បានឆ្លើយថា៖ ខ្លួនសូមបដិសេធនូវការចោទប្រកាន់ ព្រោះថាខ្លួនមិនបានចូលរួមក្នុងការប្រើអំពើហិង្សាទៅលើជនរងគ្រោះនោះទេ ដោយថ្ងៃទី១១ ខែមីនា ឆ្នាំ ២០២២ ខ្លួនបានទៅបូមទឹកដាក់ចំការជាមួយឪពុកតាំងពីម៉ោង១១ ដល់ម៉ោង ៦ ល្ងាច ។ ខ្លួនមិនមែនជាសមាជិកក្រុម TK នោះទេ ហើយខ្លួនស្គាល់ឈ្មោះ [redacted] ណោត ព្រោះធ្លាប់រៀនជាមួយគ្នា ក្រៅពីនេះខ្លួនមិនស្គាល់ឡើយ ហើយក៏មិនបានដឹងពីហេតុការណ៍ដែលបានវាយទៅលើជនរងគ្រោះដែរ ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យុទ្ធា បានឆ្លើយថា៖ ខ្លួនសូមបដិសេធនូវការចោទប្រកាន់ ព្រោះថាខ្លួនមិនបានចូលរួមក្នុងការប្រើអំពើហិង្សាទៅលើជនរងគ្រោះនោះទេ ដោយថ្ងៃទី១១ ខែមីនា ឆ្នាំ ២០២២ វេលាម៉ោង៣រសៀល ឈ្មោះ [redacted] ណោត បានពឹងឲ្យជូនទៅវត្តជ្រោយតាកែវ និងសុំខ្ចីម៉ូតូជិះដើរលេង តែខ្លួនមិនព្រមក៏បានជិះទៅជាមួយគ្នាដែរ នៅពេលទៅដល់វត្តដើមពោធិ៍ឈ្មោះ [redacted] ណោត បានទៅអង្គុយលេងជាមួយមិត្តភក្តិគាត់ប្រហែល១០នាក់ តែខ្លួនស្គាល់តែឈ្មោះ [redacted] ហុងម៉េង ប៉ុណ្ណោះ ។ លុះប្រហែល០៥នាទីក្រោយមក ឈ្មោះ [redacted] ណោត និងបក្សពួកបានចូលព្រួតវាយទៅលើជនរងគ្រោះ ហើយខ្លួនក៏មិនស្គាល់ជនរងគ្រោះដែរ ។ នៅពេលវាយគ្នានោះខ្លួនបានឃើញឈ្មោះ [redacted] ណោត វាយដោយដៃ ចំណែកឈ្មោះ [redacted] ហុងម៉េង



Scanned with CamScanner

បានវាយនឹងខ្សែក្រវ៉ាត់ ហើយខ្លួនមិនបានចូលវាយគ្នានោះទេ ។ ក្នុងសកម្មភាពវាយគ្នាខ្លួនមិនបានឃើញការប្រើដុំថ្ម ឬកាំបិតឡើយ ។ ក្រោយពេលវាយគ្នាចប់ខ្លួនបានត្រឡប់មកវិញ ដោយមិនបានដឹងគម្រោងការណ៍អ្វីនោះទេ ។ ខ្លួនមិនស្គាល់ក្រុមJTK នោះទេ ចំណែកឈ្មោះ [redacted] ណេត គ្រាន់តែជាអ្នកជិតខាងប៉ុណ្ណោះ ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហុងម៉េង បានឆ្លើយថា៖ ខ្លួនសូមបដិសេធនូវការចោទប្រកាន់ ព្រោះថាខ្លួនមិនបានចូលរួមក្នុងការប្រើអំពើហិង្សាទៅលើជនរងគ្រោះនោះទេ ដោយនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ខ្លួននៅជួយរៀបក្បឿងធ្វើផ្ទះតាំងពីព្រឹកដល់យប់ ខ្លួនមិនមានគម្រោងវាយទៅលើជនរងគ្រោះ មិនស្គាល់ឈ្មោះ វ៉ាន់ ណេត និងអ្នកដទៃដែរ ហើយខ្លួនក៏មិនស្គាល់ក្រុមJTK នោះទេ ។

-ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រ៊ីង បានបញ្ជាក់ថា៖ កាលពីថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០២២ មានឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សំណាង ត្រូវជាមិត្តភក្តិកូនប្រុសខ្លួន បានឌុបកូនមកដោយមានសភាពរបួសពេញខ្លួន ឈាមហូរតាមច្រមុះ តាមត្រចៀក និងតាមមាត់ ហើយសន្លប់ស្តូកស្តឹង ។ ពេលខ្លួនសួរក្មេងទាំងពីរនាក់នោះ ឆ្លើយកុហកថា កូនខ្លួនបានជិះម៉ូតូបុករឺម៉កគេ បន្ទាប់មកខ្លួនបានដឹកកូនទៅមន្ទីរពេទ្យបង្អែកស្រុកកោះធំ តែពេលទៅដល់ពេទ្យប្រាប់ថាកូនខ្លួនបានបាត់បង់ជីវិតហើយ ។ នៅពេលនេះខ្លួនសុំទាមទារសំណងជម្ងឺចិត្តចំនួន ៥.០០០$ (ប្រាំពាន់ដុល្លារអាមេរិក) ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] សំណាង បានបញ្ជាក់ថា៖ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ខ្លួននិងមិត្តឈ្មោះ [redacted] សុខុម , ឈ្មោះ [redacted] ម៉េងហុង និងឈ្មោះ [redacted] ណាក់ បានជិះម៉ូតូគ្នា០៤នាក់ ដើម្បីទៅលេងផ្ទះគូដណ្តឹងរបស់ឈ្មោះ [redacted] ណាក់ ។ បន្ទាប់មកខ្លួននិងគ្នា០២នាក់ទៀតបានត្រឡប់មកផ្ទះវិញ ពេលមកដល់មុខវត្តជ្រោយតាកែវ ស្រាប់តែមានជនជាប់ចោទគ្នា០៨នាក់ ជិះម៉ូតូ០៣គ្រឿង បានហៅឲ្យពួកខ្លួនឈប់ ពួកខ្លួនមិនបានឈប់នោះទេ ភ្លាមនោះក្រុមមនុស្សទាំងនោះបានជិះម៉ូតូដេញតាម និងមានកាន់ខ្សែក្រវ៉ាត់រហូតមកដល់មុខវត្តដើមពោធិ៍ក៏បានឃើញគ្នាពួកគេនៅឈរចាំមុខវត្តហើយបានយកដុំថ្មមកគប់ទៅលើឈ្មោះ [redacted] សុខុម តែគប់មិនត្រូវ បន្ទាប់មកខ្លួនបានឃើញឈ្មោះ [redacted] ម៉េងហុង ដួលម៉ូតូសន្លប់ស្តូកស្តឹងពេលពួកខ្លួនជិះត្រឡប់ក្រោយស្រាប់តែក្រុមនោះនាំគ្នាជិះរត់បាត់អស់ ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] សុខុម បានបញ្ជាក់ថា៖ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ខ្លួនបានជិះម៉ូតូជាមួយឈ្មោះ [redacted] ម៉េងហុង ទៅយកទូរសព្ទនៅផ្សារ លុះពេលត្រឡប់មកវិញក៏បានឃើញឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] ណាក់ ពេលនោះក៏នាំគ្នាទៅផ្ទះគូដណ្តឹងរបស់ឈ្មោះ [redacted] ណាក់ រួចនាំគ្នាត្រឡប់មកវិញ ។ នៅពេលមកដល់មុខវត្តជ្រោយតាកែវ ក៏បានជួបនឹងមនុស្ស០៦នាក់ បានជិះម៉ូតូដេញតាមពីក្រោយរហូតដល់វត្តដើមពោធិ៍ ហើយក៏មានបក្សពួក០៨នាក់ទៀតចេញមកស្ទាក់ និងយកដុំថ្មគប់មកលើខ្លួន តែគេចផុតក៏ត្រូវឈ្មោះ [redacted] ម៉េងហុង វិញបណ្តាលឲ្យដួលម៉ូតូ នៅពេលនោះខ្លួនបានត្រឡប់ក្រោយវិញ ស្រាប់តែពួកនោះនាំគ្នារត់គេចបាត់ទៅ ក្រោយមកខ្លួនបានបញ្ជូនឈ្មោះ [redacted] ម៉េងហុង ទៅផ្ទះតែម្តង ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] ផល្លា បានបញ្ជាក់ថា៖ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ខ្លួនបានប្រើក្មួយឈ្មោះ [redacted] មាន ទៅយកថ្លៃសាច់ជ្រូកនៅផ្សារតាខ្មៅ និងផ្សារកាច់ជ្រុង ។ ចំណែកខ្លួនបានទៅប្រមូលថ្លៃសាច់ជ្រូកនៅកោះធំ និងព្រៃធំ លុះម៉ោង៣រសៀល នៅពេលត្រឡប់មកវិញ ខ្លួនមិនបានដឹងអំពីរឿងហេតុនោះទេ ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] ស៊ិ បានបញ្ជាក់ថា៖ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ខ្លួនបានទៅបូមទឹកពោតនៅព្រែកនួ ស្ថិតនៅភូមិព្រែកតាមេម លុះដល់វេលាម៉ោង ១២ ថ្ងៃត្រង់ កូនប្រុសរបស់ខ្លួនឈ្មោះ [redacted] សាវ៉ាន់ បានយកបាយទៅឲ្យខ្លួននៅចម្ការពោត ។ កូនរបស់ខ្លួនបាននៅបូមទឹកជាមួយខ្លួនដាក់ចម្ការពោត

រហូតដល់ម៉ោង០៦ល្ងាច ទើបត្រលប់មកផ្ទះវិញជាមួយគ្នា ។ នៅពេលព្រឹកកូនរបស់ខ្លួនមិនបានមកជួយបូមទឹកជាមួយខ្លួននោះទេ ព្រោះវាជាប់រៀន ទាល់តែចេញពីសាលារៀនវិញទើបយកបាយឱ្យខ្លួនហូបចម្ការនោះ ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] ចិន្តា បានបញ្ជាក់ថា៖ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ខ្លួនទៅធ្វើការរោងចក្រកាត់ដេរ រហូតដល់ម៉ោង ១១ ទើបខ្លួនត្រលប់មកផ្ទះវិញ លុះដល់ម៉ោង ០១ នាទីរសៀល ខ្លួនត្រលប់ទៅធ្វើការរោងចក្រវិញ ។ ខ្លួនមិនបានដឹងថាកូនខ្លួនបានទៅចូលរួមសកម្មភាពវាយគ្នាជាមួយបក្ខពួកនៅភូមិដើមពោធិ៍ ឬក៏អត់នោះទេ ខ្លួនគ្រាន់តែដឹងថា កូនខ្លួនបន្ទាប់ពីចេញពីសាលារៀនវិញ ហូបបាយរួចទៅច្រូតស្មៅគោហើយ ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] ធា បានបញ្ជាក់ថា៖ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ កូនរបស់ខ្លួនឈ្មោះ [redacted] សាវ៉ាន់ បានដាក់ទឹកពោតនៅព្រែកនូ ស្ថិតនៅភូមិព្រែកតាមេម ជាមួយឪពុកបង្កើត និងប្អូនបង្កើតឈ្មោះ [redacted] ស៊ីម នឹងឈ្មោះ [redacted] វឿន (ជាអ្នកជិតខាង) លុះដល់ម៉ោង ០៦ល្ងាច ទើបកូនប្រុសរបស់ខ្លួនត្រលប់មកផ្ទះវិញ ។ ខ្លួនសូមបញ្ជាក់ថាកូនប្រុសខ្លួនមិនបានចូលរួមវាយទៅលើជនរងគ្រោះបណ្តាលឲ្យស្លាប់នោះទេ ព្រោះនៅថ្ងៃកើតហេតុនោះខ្លួនមិនបានទៅណានោះទេ ក្រៅពីទៅដាក់ទឹកពោត ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] ហោ បានបញ្ជាក់ថា៖ នៅក្នុងរឿងហេតុដែលកើតមានឡើងនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ខ្លួនពុំបានដឹង ពុំបានឃើញអ្វីនោះទេ ព្រោះនៅថ្ងៃនោះខ្លួននៅផ្ទះមើលចៅ ។ ខ្លួនគ្រាន់តែដឹងថាចៅរបស់ខ្លួនឈ្មោះ [redacted] យុទ្ធា ជាមនុស្សល្អ ស្លូតត្រង់ មិនដែលបង្ករឿងហេតុនៅក្នុងគ្រួសារក៏ដូចជាក្នុងភូមិស្រុកនោះទេ ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ភ័ស បានបញ្ជាក់ថា៖ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ឈ្មោះ [redacted] មាន នៅធ្វើការឲ្យខ្លួនមិនបានទៅណានោះទេ ។ នៅម៉ោង១១ព្រឹក ឈ្មោះ [redacted] មាន បានទៅប្រមូលលុយសាច់នៅផ្សារតាខ្មៅចាស់ និងផ្សារតាខ្មៅថ្មី រហូតដល់ម៉ោង ១ ទើបមកដល់ផ្ទះ ។ ឈ្មោះនេះមិនមានម៉ូតូធ្វើដំណើរដោយខ្លួនឯងនោះទេ ដូច្នេះពេលទៅផ្ទះម្តងៗគឺទៅជាមួយខ្លួន ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] វឿន បានបញ្ជាក់ថា៖ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ខ្លួនបានដឹកប្រេងម៉ាស៊ូតឲ្យឪពុករបស់ឈ្មោះ [redacted] សាវ៉ាន់ នៅចម្ការពោត ពេលទៅដល់ខ្លួន ពុំបានឃើញឈ្មោះ [redacted] សាវ៉ាន់ នៅចម្ការពោតនោះទេ ព្រោះវាទៅរៀនបាត់ ។ លុះដល់ម៉ោង ០៣ នាទីរសៀល ថ្ងៃដដែល ឪពុករបស់ឈ្មោះ [redacted] សាវ៉ាន់ គេឲ្យខ្លួនដឹកម៉ាស៊ូតឲ្យគាត់ម្តងទៀត ពេលខ្លួនដឹកទៅដល់ចម្ការពោត ខ្លួនក៏បានជួបឈ្មោះ [redacted] សាវ៉ាន់ នៅចម្ការពោតនោះដែរ ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ធឿន បានបញ្ជាក់ថា៖ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ខ្លួនបានទៅអង្គុយលេងផ្ទះម្តាយឪពុករបស់ឈ្មោះ [redacted] សាវ៉ាន់ លុះប្រហែលជាម៉ោង១១ព្រឹក ខ្លួនឃើញឈ្មោះ [redacted] សាវ៉ាន់ ចេញពីសាលារៀនត្រលប់មកផ្ទះវិញ ។ លុះដល់ម៉ោងប្រហែល ១២ ថ្ងៃត្រង់ ឈ្មោះ [redacted] សាវ៉ាន់ បានយកបាយទៅឲ្យឪពុកវានៅបូមទឹកចម្ការពោត រហូតដល់ម៉ោង ០៦ ល្ងាច ទើបឈ្មោះ [redacted] សាវ៉ាន់ ត្រលប់មកផ្ទះវិញជាមួយឪពុកវា និងប្អូនម្នាក់ទៀត ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ចាន់ណារីទ្ធ បានបញ្ជាក់ថា៖ នៅក្នុងរឿងហេតុក្មេងៗវាយគ្នានៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ខ្លួនពុំបានដឹង ពុំបានឃើញអ្វីនោះទេ ។ ខ្លួនគ្រាន់តែដឹងថាឈ្មោះ [redacted] យុទ្ធា ជាមនុស្សល្អ ស្លូតត្រង់ មិនដែលបង្ករឿងហេតុនៅក្នុងគ្រួសារក៏ដូចជាក្នុងភូមិស្រុកនោះទេ ។



Scanned with CamScanner

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សុលឿន បានបញ្ជាក់ថា៖ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ខ្លួនបានឃើញឈ្មោះ [redacted] សាវ៉ាន់ បានយកបាយទៅឲ្យពុករបស់វា ដែលកំពុងនៅបូមទឹកពោតនៅព្រែកន្ទ ដែលចម្ការពោតរបស់ខ្លួន និងចម្ការពោតរបស់ឪពុកវា គឺនៅជិតរំលងមួយចម្ការពីគ្នា ។ លុះវេលាម៉ោងប្រហែលជា ០៦ ល្ងាច ទើបឈ្មោះ [redacted] សាវ៉ាន់ ត្រលប់ទៅផ្ទះវិញ ខ្លួនបានឃើញឈ្មោះ [redacted] សាវ៉ាន់ នៅចម្ការពោតជាមួយឪពុកវា ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ចាន់ថុល បានបញ្ជាក់ថា៖ ក្នុងរឿងហេតុដែលកើតមានឡើងនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ខ្លួនពុំបានដឹង និងពុំបានឃើញអ្វីនោះទេ ។ ខ្លួនគ្រាន់តែដឹងថាឈ្មោះ [redacted] យុទ្ធា ជាមនុស្សល្អ ស្លូតត្រង់ មិនដែលបង្ករឿងហេតុនៅ ក្នុងគ្រួសារក៏ដូចជាក្នុងភូមិស្រុកនោះទេ ។

-សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ៖ ក្រោយពីបានសួរដេញដោលនាពេលសវនាការរួចជនជាប់ចោទបានឆ្លើយបដិសេធថាមិនបានប្រព្រឹត្តដូចជាការចោទប្រកាន់នោះទេ ឃើញថា ចម្លើយនេះជាចម្លើយដោះសារតែប៉ុណ្ណោះ ពុំមានសាក្សីនិងភស្តុតាងដោះបន្ទុកគ្រប់គ្រាន់ដែលគប្បីឲ្យជឿបានឡើយ ។ ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនជាប់ចោទពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។ រក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ៖ ៩៨៥ ដកសព/២២ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល និងស្នើសុំឲ្យតុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទតាមច្បាប់ ។

-សេចក្តីសន្និដ្ឋានការពារក្តីរបស់មេធាវីការពារក្តីឲ្យជនជាប់ចោទ៖ ក្រោយពីបានសួរដេញដោលនាពេលសវនាការរួចមក តាមចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយរបស់សាក្សីឃើញថាចម្លើយមិនដូចគ្នា ហើយជនរងគ្រោះគឺអាចបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍ ព្រោះថាមិនមានស្នាមជុំថ្ម មិនមានស្នាមកាំបិត ។ ចម្លើយដែលកូនក្តីខ្លួនបានឆ្លើយនៅដំណាក់មន្ត្រីនគរបាលនោះ គឺដោយសារកូនក្តីខ្លួនមានការភ័យខ្លាច ហើយចម្លើយសាក្សីក៏មិនបានឃើញជនជាប់ចោទប្រព្រឹត្តទៅលើជនរងគ្រោះច្បាស់ ។ ដូច្នេះស្នើសុំឲ្យតុលាការឲ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់ ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់ចម្លើយសាក្សី
ក្រោយពីបានស្តាប់ការសន្និដ្ឋានទោសរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់ការសន្និដ្ឋានការពាររបស់មេធាវីការពារក្តីឲ្យជនជាប់ចោទ
ក្រោយពីបានពិនិត្យភស្តុតាងនានា
ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់
ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

## **សំអាងហេតុ**

១-តាមអង្គហេតុបានបង្ហាញថា កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ស្ថិតនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល ពិតជាកើតមាននូវអំពើ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណៈភាពនៃជនរងគ្រោះ ប្រាកដមែន ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] ណោត

, ឈ្មោះ [redacted] សុខចាន់ , ឈ្មោះ [redacted] ហុងម៉េង , ឈ្មោះ [redacted] យុទ្ធា , ឈ្មោះ [redacted] ចិន , ឈ្មោះ [redacted] វត្ត , ឈ្មោះ [redacted] វិសាល , ឈ្មោះ [redacted] ទ្រី , ឈ្មោះ [redacted] សាវ៉ាន់ , ឈ្មោះ [redacted] មាស , ឈ្មោះ [redacted] មាន និងឈ្មោះ [redacted] វណ្ណៈ បានធ្វើសកម្មភាពជាក្រុមវាយតប់ទៅលើជនរងគ្រោះឈ្មោះ [redacted] ម៉េងហុង បណ្តាលឲ្យមានរបួសធ្ងន់ធ្ងរ ក្រោយមកបានបញ្ជូនទៅមន្ទីរពេទ្យ ហើយជនរងគ្រោះក៏បានស្លាប់បាត់បង់ជីវិត ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ណោត , ឈ្មោះ [redacted] សុខចាន់ , ឈ្មោះ [redacted] មាស , ឈ្មោះ [redacted] ហុងម៉េង និងឈ្មោះ [redacted] វិសាល គឺបានព្យាយាមឆ្លើយដោះសានឹងការចោទប្រកាន់ថាខ្លួនមិនបានចូលរួមប្រព្រឹត្តវាយតប់ទៅលើជនរងគ្រោះនោះទេ ឃើញថាការឆ្លើយដោះសានេះគឺពុំមានសាក្សីនិងភស្តុតាងដោះបន្ទុកគ្រប់គ្រាន់ឡើយ ព្រោះថាចម្លើយនេះមានភាពផ្ទុយគ្នាទៅនឹងចម្លើយរបស់ខ្លួននៅដំណាក់កាលមន្ត្រីនគរបាល ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យុទ្ធា , ឈ្មោះ [redacted] សាវ៉ាន់ និងឈ្មោះ [redacted] មាន បានឆ្លើយបដិសេធថាខ្លួនមិនប្រព្រឹត្តដូចជាការចោទប្រកាន់នោះទេ ដោយនៅពេលកើតហេតុ គឺខ្លួនមិនបាននៅកន្លែងកើតហេតុឡើយ ឃើញថា ចម្លើយដោះសានេះអាចឲ្យតុលាការលើកយកមកពិចារណាបាន ព្រោះថាចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់សាក្សីឈ្មោះ [redacted] ចិន្តា , ឈ្មោះ [redacted] ហោ , ឈ្មោះ [redacted] ធា , ឈ្មោះ [redacted] ស៊ិ, ឈ្មោះ [redacted] ក័ស និងឈ្មោះ [redacted] ផល្លា ។

៤-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីង គឺមិនបានដឹងនៅហេតុការណ៍កើតឡើងផ្ទាល់នោះ ហើយក៏មិនបានដឹងថាអ្នកណាវាយមកលើជនរងគ្រោះដែរ ។ ឯចម្លើយរបស់សាក្សីឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សំណាង គឺគ្រាន់តែបានឃើញក្រុមជនជាប់ចោទមានគ្នា ៨នាក់ តែមិនដឹងថាអ្នកណាជាអ្នកយកដុំថ្មគប់ទៅលើជនរងគ្រោះនោះទេ ។ ដូច្នេះឃើញថា ចម្លើយទាំងនេះមានភាពពុំច្បាស់លាស់ ដែលអាចឲ្យតុលាការលើកយកមកពិចារណាទេ ។

៥-ជនជាប់ចោទឈ្មោះ [redacted] ចិន , ឈ្មោះ [redacted] វត្ត , ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] វណ្ណៈ ត្រូវបានតុលាការធ្វើការកោះហៅឲ្យចូលខ្លួនមកឆ្លើយដោះសានឹងការចោទប្រកាន់ តែជនទាំងនេះពុំព្រមចូលខ្លួនមកឡើយ ដែលបង្ហាញឲ្យឃើញថាជននេះមានបំណងគេចវេសពីការពិត ។

៦-ទាំងចម្លើយរបស់ជនជាប់ចោទ , ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី , ចម្លើយរបស់សាក្សី និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចកំណត់បានថា ជនជាប់ចោទឈ្មោះ [redacted] ណោត , ឈ្មោះ [redacted] សុខចាន់ , ឈ្មោះ [redacted] មាស , ឈ្មោះ [redacted] ហុងម៉េង , ឈ្មោះ [redacted] វិសាល , ឈ្មោះ [redacted] ចិន , ឈ្មោះ [redacted] វត្ត , ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ណ្ណៈ ពិតជាបានប្រព្រឹត្តបទល្មើសប្រាកដមែន ។

៧-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលបញ្ជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ប្រាកដមែន។

៨-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ណោត , ឈ្មោះ [redacted] សុខចាន់ , ឈ្មោះ [redacted] មាស , ឈ្មោះ [redacted] ហុងម៉េង , ឈ្មោះ [redacted] វិសាល , ឈ្មោះ [redacted] ចិន , ឈ្មោះ [redacted] វត្ត , ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] វណ្ណៈ បានស្តែងឡើងដោយមានចេតនាវាយតប់ទៅលើជនរងគ្រោះ បណ្តាលឲ្យជនរងគ្រោះរងរបួស និងស្លាប់បាត់បង់ជីវិត ដែលអំពើនេះច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ និងមានចែងក្នុងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

៩-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] យុទ្ធា , ឈ្មោះ [redacted] សាវ៉ាន់ និងឈ្មោះ [redacted] មាន គឺពុំមានធាតុផ្សំជាបទល្មើស ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ តាមមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ឡើយ ព្រោះថា ជនជាប់ចោទពុំបានចូលរួមធ្វើសកម្មភាពល្មើសទៅលើជនរងគ្រោះ ហើយនៅពេលកើតហេតុក៏ពុំមានវត្តមាននៃជនជាប់ចោទដែរ ។



Scanned with CamScanner

១០-ជនជាប់ចោទជានីតិជននិងអនីតិជន ហើយបានប្រព្រឹត្តអំពើល្មើសដោយមានចេតនា និងការយល់ដឹងពីអំពើរបស់ខ្លួន ដូច្នេះជននេះត្រូវទទួលខុសត្រូវនូវទង្វើដែលខ្លួនបានប្រព្រឹត្តចំពោះច្បាប់ ។

១១-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ណោត , ឈ្មោះ [redacted] សុខចាន់ , ឈ្មោះ [redacted] មាស , ឈ្មោះ [redacted] ហុងម៉េង , ឈ្មោះ [redacted] វិសាល , ឈ្មោះ [redacted] ចិន , ឈ្មោះ [redacted] វត្ត , ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] វណ្ណៈ ដែលមានសាវតាដូចខាង ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

១២-ពុំមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] យុទ្ធា , ឈ្មោះ [redacted] សាវ៉ាន់ និងឈ្មោះ [redacted] មាន ដែលមានសាវតាដូចខាង ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

១៣-គប្បីតុលាការប្រកាសទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] ណោត , ឈ្មោះ [redacted] មាស , ឈ្មោះ [redacted] សុចាន់ ក្នុងកំរិតដាក់ពន្ធនាគារ ៣ឆ្នាំ៦ខែ , ឈ្មោះ [redacted] វិសាល , [redacted] ហុងម៉េង ក្នុងកំរិតដាក់ពន្ធនាគារ ៣ឆ្នាំ៦ខែ តែត្រូវអនុវត្តទោសព្យួរធម្មតា , ឈ្មោះ [redacted] ទ្រី , ឈ្មោះ [redacted] ចិន , ឈ្មោះ [redacted] វត្ត ក្នុងកំរិតដាក់ពន្ធនាគារ ៧ឆ្នាំ , ឈ្មោះ [redacted] ណ្ណៈ ក្នុងកំរិតដាក់ពន្ធនាគារ ៣ឆ្នាំ៦ខែ ដោយពិចារណាទៅលើភាពធ្ងន់ស្រាលនៃបទល្មើស និងសកម្មភាពល្មើសរបស់ជនជាប់ចោទដូចខាងក្រោម:

-អំពើល្មើសរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់ រូបរាងកាយ អាយុជីវិតរបស់អ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ។

-សកម្មភាពល្មើសបានបង្កឲ្យជនរងគ្រោះបាត់បង់ជីវិតពេលបញ្ជូនទៅមន្ទីរពេទ្យ ។

-ជនជាប់ចោទឈ្មោះ [redacted] ណោត មានអាយុ១៨ឆ្នាំ វ័យក្មេងពុំបានគិតពិចារណាឲ្យបានវែងឆ្ងាយ និងស្ថិតក្នុងវ័យសិក្សា ។

-ជនជាប់ចោទឈ្មោះ [redacted] មាស , ឈ្មោះ [redacted] សុចាន់ , ឈ្មោះ [redacted] វិសាល , ឈ្មោះ [redacted] ហុងម៉េង និងឈ្មោះ [redacted] វណ្ណៈ គិតមកដល់ថ្ងៃប្រព្រឹត្តបទល្មើស គឺមានអាយុត្រឹមតែ ១៦ឆ្នាំ ១៧ឆ្នាំ ប៉ុណ្ណោះ ជាអនីតិជន ដោយយោងតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ អប្បបរមានិងអតិបរមា នៃទោសត្រូវបន្ថយមកត្រឹមពាក់កណ្តាល ។

-ជនជាប់ចោទឈ្មោះ [redacted] ទ្រី , ឈ្មោះ [redacted] ន , ឈ្មោះ [redacted] វត្ត , ឈ្មោះ [redacted] វណ្ណៈ បានគេចវេសពុំព្រមចូលខ្លួនតាមការកោះហៅពីតុលាការគ្រប់នីតិវិធី ។ មូលហេតុទាំងនេះនាំឲ្យតុលាការ ពិចារណាប្រកាសទោសក្នុងកំរិតខាងលើដល់ជនជាប់ចោទ ។

១៤-វត្ថុតាងគប្បីសម្រេចរឹបអូសរួមមាន៖ ទូរសព្ទចំនួន ០១គ្រឿងម៉ាក(Iphone 7Plus) ពណ៌ទឹកប្រាក់មិនប្រក្រតី ។

១៥-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រ៊ីង បានទាមទារសំណងជម្ងឺសរុបជាប្រាក់ចំនួន ៥.០០០$ (ប្រាំពាន់ដុល្លារអាមេរិក) ឃើញថា បណ្តឹងនេះធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមមាត្រា១៣ , មាត្រា១៤ , មាត្រា១៥ , មាត្រា២១ និងមាត្រា២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការអាចពិនិត្យនិងសម្រេចបានតាមមាត្រា២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ តាមការពិនិត្យឃើញថា ការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី មានចំនួន ច្រើនដែលគប្បីតុលាការបន្ធូបន្ថយឲ្យបានសមស្របទៅនឹងទំហំព្យសនៈកម្មជាក់ស្តែង ។



Scanned with CamScanner

១៦-ជនជាប់ចោទឈ្មោះ [redacted] ទ្រី , ឈ្មោះ [redacted] ចិន , ឈ្មោះ [redacted] រ័ត្ន និងឈ្មោះ [redacted] វណ្ណៈ ដែលមានសាវតាជាតិដូចខាងលើ មានកំរិតទោសចាប់ពី ១ឆ្នាំ ដោយគ្មានការព្យួរទោស ហើយជននេះបានរត់គេចខ្លួន ក្រោយពេលប្រព្រឹត្តបទល្មើស និងមានភស្តុតាងច្បាស់លាស់ថា ជននេះពិតជាបានប្រព្រឹត្តបទល្មើស ។ ហេតុនេះ តុលាការគប្បីចេញដីកាបង្គាប់ចាប់ខ្លួនជននេះ និងយកមកឃុំក្នុងពន្ធនាគា តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

១៧-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ៖ រក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ ៩៨៥ ដកសព/២២ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល និងស្នើសុំឲ្យតុលាការសម្រេចតាមច្បាប់ ។ គប្បីតុលាការពិចារណា ។

១៨-សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីឲ្យជនជាប់ចោទ៖ ស្នើសុំឲ្យតុលាការ ឲ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់ ។ គប្បីតុលាការពិចារណា ។

១៩-សម្ដីចុងក្រោយរបស់ជនជាប់ចោទ៖ ស្នើសុំឲ្យតុលាការលើកលែងចោទប្រកាន់ ។ គប្បីតុលាការពិចារណា ។

## សម្រេច

១-ផ្ដន្ទាទោសលើជនជាប់ចោទ៖

១.១.ឈ្មោះ [redacted] ណោត ហៅ ឆែប ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] វ៉ាន់ (រស់) ម្ដាយ ឈ្មោះ [redacted] លាងហ៊ី (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ឃុំខ្លួន១៧.០៣.២២)

ដាក់ពន្ធនាគារកំណត់រយៈពេល ៣(បី)ឆ្នាំនិង៦(ប្រាំមួយ)ខែ ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២២៤ និងមាត្រា៩៣ , មាត្រា៩៤ នៃក្រមព្រហ្មទណ្ឌ ។

១.២.ឈ្មោះ [redacted] មាស ហៅ វេហា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ជី (រស់) ម្ដាយឈ្មោះ [redacted] តា (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន ។ (ឃុំខ្លួន ១៩.១២.២០២២)

១.៣.ឈ្មោះ [redacted] សុចាន់ ហៅ តន ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតនិង ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ឡាត់ (រស់) ម្ដាយឈ្មោះ [redacted] ន (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។ (ឃុំខ្លួន១៧.០៣.២២)

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ៣(បី)ឆ្នាំនិង៦(ប្រាំមួយ)ខែ ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២២៤ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ។

១.៤.ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ស្រ៊ុ (រស់) ម្ដាយឈ្មោះ [redacted] ថន (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)



Scanned with CamScanner

១.៥.ឈ្មោះ [redacted] ហុងម៉េង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើ [redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្នភូមិកោ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ស្រ៊ូ (រស់) ម្តាយឈ្មោះ [redacted] ម៉ុន (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ដាក់ពន្ធនាគារក្នុងម្នាក់កំណត់រយៈពេល ៣(បី)ឆ្នាំនិង៦(ប្រាំមួយ)ខែ តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២២៤ , មាត្រា១៦០ , មាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ ។

១.៦.ឈ្មោះ [redacted] ទ្រី ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈឈ្មោះ [redacted] ពី (រស់) ម្តាយ ឈ្មោះ [redacted] គាន (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (គេចខ្លួន)

១.៧.ឈ្មោះ [redacted] ចិន ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈឈ្មោះ [redacted] ចិន (រស់) ម្តាយឈ្មោះ [redacted] ថេម (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (គេចខ្លួន)

១.៨.ឈ្មោះ [redacted] វត្ត ហៅ ហាត់ វឌ្ឍនា ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] ស្រាម (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (គេចខ្លួន)

ដាក់ពន្ធនាគារក្នុងម្នាក់កំណត់រយៈពេល ៧(ប្រាំពីរ)ឆ្នាំ ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

១.៩.ឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ជាអនីតិជន ទោសពីមុនគ្មាន ។ (គេចខ្លួន)

ដាក់ពន្ធនាគារក្នុងម្នាក់កំណត់រយៈពេល ៣(បី)ឆ្នាំនិង៦(ប្រាំមួយ)ខែ ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២២៤ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ។

២-ឲ្យជនជាប់ចោទ៖

២-១-ឈ្មោះ [redacted] យុទ្ធា ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ជិនដៀង (រស់) ម្តាយឈ្មោះ [redacted] ចិន្តា (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

២-២-ឈ្មោះ [redacted] សាវ៉ាន់ ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ស (រស់) ម្តាយឈ្មោះ [redacted] ធា (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)



Scanned with CamScanner

២-៣-ឈ្មោះ [redacted]មាន ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted]ម៉េង (រស់) ម្តាយឈ្មោះ [redacted] ហៀក (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

រួចខ្លួនពីបទចោទប្រកាន់ ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

៣-វត្ថុតាងដែលត្រូវរឹបអូសមាន៖ ទូរសព្ទចំនួន ០១គ្រឿងម៉ាក(Iphone 7Plus) ពណ៌ទឹកប្រាក់មិនប្រក្រតី ។

៤-បង្គាប់ឲ្យឈ្មោះ [redacted]ណោត , ឈ្មោះ [redacted] សុចាន់ និងអាណាព្យាបាល , ឈ្មោះ [redacted]មាស និងអាណាព្យាបាល , ឈ្មោះ [redacted]ហុងម៉េង និងអាណាព្យាបាល , ឈ្មោះ [redacted] ចិន , ឈ្មោះ [redacted] វុត្ថ , ឈ្មោះ [redacted]វិសាល និងអាណាព្យាបាល , ឈ្មោះ [redacted]ទ្រី , ឈ្មោះ [redacted]វណ្ណៈ និងអាណាព្យាបាល ដែលមានសាវតាជាតិដូចខាងលើ រួមគ្នាសងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ២០.០០០.០០០៛ (ម្ភៃលានរៀល) ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រ៊ង សំណើលើសពីនេះត្រូវបដិសេធចោល ។

៥-បង្គាប់ឲ្យចាប់-ឃុំខ្លួនឈ្មោះ [redacted]ទ្រី , ឈ្មោះ [redacted]វណ្ណៈ , ឈ្មោះ [redacted]វុត្ថ ហៅ [redacted]វឌ្ឍនា និងឈ្មោះ [redacted] ចិន ដែលមានសាវតាជាតិដូចខាងលើ ចាប់ពីថ្ងៃប្រកាស់សាលក្រមនេះតទៅ តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះប្រកាសនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ណោត , ឈ្មោះ [redacted]សុចាន់ , ឈ្មោះ [redacted]មាស , ឈ្មោះ [redacted]មាន និងដើមបណ្តឹងរដ្ឋប្បវេណី និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted]ហុងម៉េង , ឈ្មោះ [redacted]បុទ្ធរ៉ា , ឈ្មោះ [redacted] ចិន , ឈ្មោះ [redacted] វុត្ថ , ឈ្មោះ [redacted]វិសាល, ឈ្មោះ [redacted]ទ្រី , ឈ្មោះ [redacted]សារ៉ាន់ , និងឈ្មោះ [redacted] វណ្ណៈ បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា៖ |

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅខេត្តកណ្តាល, ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

កណ្តាល, ថ្ងៃទី 21 ខែ 02 ឆ្នាំ 2023

ក្រឡាបញ្ជី

[redacted]